# ក្រសួងពាណិជ្ជកម្ម

អាសយដ្ឋាន: ឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី វិថីក្រសួងពាណិជ្ជកម្ម( ១១៣បេ)
សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរសព្ទ័ និងទូរសារ ៖ (៨៥៥)០២៣ ៨៦៦ ៤២៥
អ៊ីម៉ែល ៖ info.admmoc@gmail.com
គេហទំព័រ ៖ www.moc.gov.kh

# វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងពាណិជ្ជកម្ម**<br>• នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម<br>- អាសយដ្ឋាន: ឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ : ០២៣ ៨៦៦ ០៥០, ០២៣ ៨៦៦ ៥៩៨, ០២៣ ៨៦៦ ៤៦០<br>- អ៊ីម៉ែល : br.moc.cambodia@gmail.com<br>- គេហទំព័រ : www.businessregistrationmoc.gov.kh |
| គោលបំណង នៃការផ្តល់សេវា | • ផ្តល់នីតិបុគ្គលិកលក្ខណៈជូនដល់សហគ្រាសពាណិជ្ជកម្មដោយចេញជូននូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម<br>• កាន់កាប់បញ្ជីពាណិជ្ជកម្ម គ្រប់គ្រងទិន្នន័យឈ្មោះក្រុមហ៊ុន-សហគ្រាសពាណិជ្ជកម្ម<br>• ចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងតាមដានសកម្មភាពពាណិជ្ជកម្ម |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពី ការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម<br>• ព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពី ការប្រកាសឱ្យប្រើនូវច្បាប់ស្តីពី វិសោធនកម្មលើច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម<br>• ព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ស្តីពី ការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម<br>• ប្រកាសលេខ ០៤២ ពណ.ចបព.ប្រក ចុះថ្ងៃទី២៩ខែមករាឆ្នាំ២០១៥ ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ ២៤០ ពណ.ចបព.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការបង្កើតបញ្ជរតែមួយលើការងារចុះបញ្ជីពាណិជ្ជកម្ម<br>• ប្រកាសលេខ ១០៤ MOC / SM 2008 ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨ ស្តីពី ការបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ ០៩៩ MOC / SM 2008 ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៨ ស្តីពី បែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុនពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការកែប្រែ កម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងផ្តល់ប្រកាសរួមលេខ ៩៨៥<br>• សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ ក្រសួងពាណិជ្ជកម្ម<br>• សេចក្តីជូនដំណឹងលេខ ០៨៤៩ MOC / SM 2008 ចុះថ្ងៃទី០៨ ខែមេសា |

| | |
|---|---|
| | ឆ្នាំ២០០៨ ស្តីពីការមកប្តូរវិញ្ញាបនបត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមគំរូថ្មី និង ការមកបំពេញប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម<br>• សេចក្តីជូនដំណឹងលេខ៣៧៧៣ ពណ.ចបព ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់អត្តលេខចុះបញ្ជីពាណិជ្ជកម្មថ្មី |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះ ជាមុខរបរខ្លួនជាប្រចាំ |
| **ស្តង់ដាសេវា** | • ចុះបញ្ជីពាណិជ្ជកម្មដូចខាងក្រោម៖<br>- សហគ្រាសឯកបុគ្គលជាប់ពន្ធលើប្រាក់ចំណេញ<br>- សាខា ឬការិយាល័យតំណាងក្រុមហ៊ុនបរទេស<br>- ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ<br>- ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត<br>- ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត/សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត<br>- ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត<br>- គ្រឹះស្ថានសាធារណៈ<br>- ក្រុមហ៊ុនរដ្ឋ<br>- ក្រុមហ៊ុនចម្រុះ<br>• រយៈពេលផ្តល់សេវាពី ៣ ទៅ ៥ថ្ងៃ ក្នុងថ្ងៃធ្វើការ<br>• កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្មត្រូវបានកំណត់ដូចតទៅ៖<br>I.<br>ក- <u>ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម</u> :<br>១- ក្រុមហ៊ុនពាណិជ្ជកម្ម ឬ ការិយាល័យតំណាង ឬ សាខាក្រុមហ៊ុនបរទេស………………………………………… ១.៦៨០.០០០ រៀល<br>២- សហគ្រាសឯកបុគ្គលឬពាណិជ្ជករដែលជាប់ពន្ធលើប្រាក់ចំណេញ ……………………………………………………. ៣០០.០០០ រៀល<br>ខ- <u>លុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម</u> :<br>១- ក្រុមហ៊ុនពាណិជ្ជកម្មឬវិនិយោគ ឬ ការិយាល័យតំណាង ឬ សាខាក្រុមហ៊ុនបរទេស………………………………. ៤៨០.០០០ រៀល<br>២- សហគ្រាសឯកបុគ្គលឬពាណិជ្ជករដែលជាប់ពន្ធលើប្រាក់ចំណេញ ……………………………………………………. ១៥០.០០០ រៀល<br>គ- <u>ការសុំវិញ្ញាបនបត្រផ្សេងៗ</u> :<br>១- ក្រុមហ៊ុនពាណិជ្ជកម្ម :<br>១.១- ការកែប្រែផ្លាស់ប្តូរភាគហ៊ុន……………….. ៨០០.០០០ រៀល<br>១.២- ការកែប្រែផ្សេងៗ (អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ ចំនួនកូប៉ុង ទីស្នាក់ការ ដើមទុន ។ល។ ………… ២៤០.០០០ រៀល<br>១.៣- ពិន័យការមិនបំពេញបែបបទក្នុងការផ្លាស់ប្តូរកែប្រែផ្សេងៗនៅក្រសួង ពាណិជ្ជកម្ម………………………… ៥០០.០០០ រៀល<br>១.៤- ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក………… ៤៨០.០០០ រៀល<br>២- សហគ្រាសឯកបុគ្គល ឬពាណិជ្ជករដែលជាប់ពន្ធលើប្រាក់ ……………………………………………………. ១០០.០០០ រៀល |

| | |
|---|---|
| | ឃ- <u>ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ</u> :<br>១- សេវាតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ……………………. ៨០.០០០ រៀល<br>២- ការពិន័យចំពោះការមិនតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ…………………….<br>……………………………………………… ១.០០០.០០០ រៀល<br>ង- <u>ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម</u> :<br>………………………………………………………. ៨០.០០០ រៀល<br>ច- <u>ទទួលពាក្យដើម្បីសម្របសម្រួលដោះស្រាយវិវាទនិងរក្សាការកែប្រែផ្សេងៗ</u>………………………………………… ១.០០០.០០០ រៀល<br>ឆ- <u>ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស</u>…………. ៤០.០០០ រៀល<br>II. សេវាពិគ្រោះយោបល់<br>ក- សេវាពិគ្រោះយោបល់ចុះបញ្ជីពាណិជ្ជកម្ម(តាមការស្នើសុំ)<br>...........................................................................៤០០ ០០០រៀល<br>- ពិនិត្យនិងបញ្ជាក់លើភាពស្របច្បាប់នៃឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម<br>- បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យាឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន<br>- ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន<br>- ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់<br>ខ- សេវាពិគ្រោះយោបល់ទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងការបញ្ជាក់ផ្សេងៗ(តាមការស្នើសុំ)……………………………២០០ ០០០រៀល<br>- បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យា ឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន<br>- ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន<br>- ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន<br>គ- សេវារៀបចំលក្ខន្តិកៈក្រុមហ៊ុន(ចុះបញ្ជីពាណិជ្ជកម្មថ្មី និងការកែប្រែលក្ខន្តិកៈ)តាមការស្នើសុំ.........................................៤០០ ០០០រៀល |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | សំណុំឯកសារចុះបញ្ជីពាណិជ្ជកម្មដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មចាទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម៖<br>**ក) សម្រាប់ការចុះបញ្ជីក្រុមហ៊ុន**<br>១. ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតធនាគារជាដើម<br>២. លក្ខន្តិកៈក្រុមហ៊ុន<br>៣. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ក្រុមហ៊ុន និងអភិបាល<br>៤. រូបថត ៤x៦<br>៥. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា |

៦. ករណីម្ចាស់ហ៊ុនជានីតិបុគ្គល
   - ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់
   - លិខិតតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុនច្បាប់ដើម

៧. ក្រុមហ៊ុនត្រូវធ្វើលក្ខន្តិកៈច្បាប់ដើមចំនួន០២ច្បាប់ រួមជាមួយលិខិតច្បាប់ដើមបញ្ជាក់អំពីឈ្មោះគណនីរបស់ក្រុមហ៊ុន ដែលបានបើកនៅធនាគារណាមួយចំនួន០១ច្បាប់ ឲ្យមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។ ក្នុងបីរវេលានេះប្រសិនបើនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលលក្ខន្តិកៈច្បាប់ដើមទេ ក្រសួងពាណិជ្ជកម្មអាចទំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម។ (សម្គាល់ ៖ ចំណុចទី៧នេះ កំពុងធ្វើការកែសម្រួល និងស្នើខ្ញុំឯកឧត្តមរដ្ឋមន្ត្រីចុះហត្ថលេខាលើប្រកាសថ្មីនៅក្នុងសប្តាហ៍ទី៤ នៃខែឧសភា ឆ្នាំ២០១៦នេះ)។

**ខ) ការចុះបញ្ជីសាខា ឬការិយាល័យតំណាង**

១. ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតជនាគារដោដើម
២. ច្បាប់ចម្លងឯកសារគតិយុត្តិ នៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ ដែលទទួលស្គាល់ដោយច្បាប់
៣. សេចក្តីសម្រេចរបស់ក្រុមហ៊ុដើមបង្កើតសាខា ឬការិយាល័យតំណាង និងតែតាំងនាយកសាខា ឬការិយាល័យតំណាង
៤. អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនរបស់នាយកការិយាល័យតំណាង ឬសាខា
៥. រូបថត ៤x៦
៦. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់នាយកការិយាល័យតំណាង ឬសាខា ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**គ) ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ**

១. ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតជនាគារដោដើម
២. កិច្ចសន្យាបង្កើតក្រុមហ៊ុន
៣. អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែនរបស់សហកម្មសិទ្ធិករ និងអ្នកគ្រប់គ្រង
៤. រូបថត ៤x៦
៥. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកគ្រប់គ្រង ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
៦. ករណីសហកម្មសិទ្ធិករជានីតិបុគ្គល
   - ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់
   - លិខិតតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករច្បាប់ដើម
៧. ក្រុមហ៊ុនត្រូវធ្វើកិច្ចសន្យាក្រុមហ៊ុនច្បាប់ដើមចំនួន០២ច្បាប់ ឲ្យមក

<table>
<tr>
<td></td>
<td>នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្នុងអំឡុងពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។ ក្នុងថិរវេលានេះប្រសិនបើនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលកិច្ចសន្យាក្រុមហ៊ុនច្បាប់ដើមទេ ក្រសួងពាណិជ្ជកម្មអាចទំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម។<br>ឃ) ការចុះបញ្ជីសហគ្រាសឯកបុគ្គល<br>១. ឯកសារបញ្ជាក់អាសយដ្ឋានដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក ឬកិច្ចសន្យាជួលផ្ទះឬអគារ លិខិតធនាគារជាដើម<br>២. អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ<br>៣. រូបថត ៤x៦ របស់ឯកកម្មសិទ្ធិករ<br>៤. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់ឯកកម្មសិទ្ធិករ ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។</td>
</tr>
<tr>
<td>យោបល់</td>
<td>• រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថាន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួន នៅព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះបញ្ជីពាណិជ្ជកម្ម នៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម សម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្មពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ៖ www.businessregistration.moc.gov.kh។ ក្នុងករណីខកខាននឹងត្រូវផ្តន្ទាទោសទៅតាមការកំណត់របស់ច្បាប់។<br>• រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមិនបានស្នើសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ នឹងត្រូវប្តឹងទៅតុលាការ អំពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់<br>• ក្រុមហ៊ុនដែលបានចុះបញ្ជីត្រូវមានកាតព្វកិច្ច តម្កល់ប្រតិវេទ៍ប្រចាំឆ្នាំដែលទាក់ទងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម (តាមប្រព័ន្ធស្វ័យប្រវត្តកម្ម)។</td>
</tr>
</table>

# ចុះបញ្ជីម៉ាក និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ

| | |
|---|---|
| **ឈ្មោះសេវា** | ចុះបញ្ជីម៉ាក និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ |
| **ក្រសួង/ស្ថាប័នផ្តល់សេវា** | **ក្រសួងពាណិជ្ជកម្ម**<br>• នាយកដ្ឋានកម្មសិទ្ធិបញ្ញា<br>- អាសយដ្ឋាន: ឡូត៍លេខ១៩-៦១វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ: (៨៥៥) ២៣ ៨៦៦ ១១៥<br>- ទូរសារ: (៨៥៥) ២៣ ៨៦៦ ១១៤<br>- អ៊ីមែល: cambodiaip.dip@gmail.com |
| **គោលបំណងនៃការផ្តល់សេវា** | ការពារម៉ាក និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ ដែលបានចុះក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើតការប្រើប្រាស់ម៉ាកពាណិជ្ជនាម និងម៉ាកទំនិញ សម្គាល់ភូមិសាស្ត្រ និងជាពិសេសជួយជំរុញ និងការពារសហគ្រាសធុនតូច និងមធ្យម សមាគមផលិតករឲ្យផលិតទំនិញបានច្រើនបម្រើ ដល់តម្រូវការក្នុងប្រទេស និងអាចឈានឡើងដល់ការនាំចេញ និង ទាក់ទាញវិនិយោគពីបរទេស |
| **មូលដ្ឋានគតិយុត្ត** | • ព្រះរាជក្រមលេខ នស/រកប/០២០២/០០៦ ចុះថ្ងៃទី០៧ខែកុម្ភៈឆ្នាំ២០០២ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាកពាណិជ្ជនាម និងអំពីនៃការប្រកួតប្រជែងមិនស្មោះត្រង់<br>• អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់<br>• ប្រកាសអន្តរក្រសួងលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពី ការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ខែធ្នូ ឆ្នាំ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ១០៥MOC/SM2009ចុះថ្ងៃទី១៨ខែឧសភាឆ្នាំ២០០៩ស្តីពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រ |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | រូបវន្តបុគ្គល ឬ នីតិបុគ្គល |
| **ស្តង់ដាសេវា** | • ការផ្តល់សេវាចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ស្របតាមស្តង់ដារអន្តរជាតិដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានផ្តល់នូវប្រព័ន្ធ IPAS ប្រើប្រាស់ជាមួយ Computer ដែលពិនិត្យម៉ាកតាមជំហាននីមួយៗ ដែលរួមមានអត្ថន័យ សម្លេងអាន រូបភាពមើលឃើញ (Appearance) និងធ្វើការប្រៀបធៀបមុខទំនិញ និងសេវាដែលដូច ឬប្រហាក់ប្រហែល ឬមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ទន្ទឹមនេះ ត្រូវពិនិត្យមើលពាក្យស្លាក ពាក្យទូទៅ (Generic Term) ប្រភេទ (Kind) បរិមាណ (Quantity) គុណភាព (Quality) និងចំណុចផ្សេងៗជាច្រើន ទៀត តាមស្តង់ដារអន្តរជាតិ<br>• ចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជាមានរយៈពេល ០៦ ទៅ ០៩ ខែ ឬលើសពីរយៈពេលនេះ ក្នុងករណីមានភាគីទីបីទំនាស់ ឬការទទួលពាក្យមានការកើនឡើងច្រើន ឬការកែតម្រូវពាក្យស្នើសុំរបស់អ្នកដាក់ពាក្យ បើប្រៀបធៀបទៅនឹងការចុះបញ្ជីម៉ាកនៅបណ្តាប្រទេសអាស៊ាន មានរយៈពេលចាប់ |

| | |
|---|---|
| | ពី ៦ខែ ទៅ ១២ ខែ ចំណែកឯនៅសហរដ្ឋអាមេរិក មានរយៈពេល១២ ខែ ទៅ១៨ខែ<br>**កម្រៃនៃការចុះបញ្ជីម៉ាកមានដូចខាងក្រោម៖**<br>**I-ការចុះបញ្ជីម៉ាក**<br>១. ការដាក់ពាក្យសុំចុះបញ្ជី សម្រាប់មួយម៉ាក និងមួយជំពូកមានតម្លៃ …………………………………………………… ៣០ ០០០រៀល<br>២. ការចុះបញ្ជីម៉ាកដែលមានសុពលភាព ១០ ឆ្នាំ សម្រាប់មួយម៉ាក និងមួយជំពូកមានតម្លៃ……………………………… ២៦០ ០០០រៀល<br>៣. កម្រៃរដ្ឋបាលក្នុងការបោះពុម្ព (ការចុះបញ្ជីម៉ាក ការចុះបញ្ជីម៉ាកសារជាថ្មី ការលុបម៉ាកចេញពីបញ្ជី) សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ……………………………………… ១២០ ០០០រៀល<br>**II-ការបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក**<br>ការដាក់ពាក្យ និងការបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ……. ៦០ ០០០រៀល<br>**III-ការផ្លាស់ប្តូរផ្សេងៗ**<br>- ការកត់ត្រាការផ្ទេរកម្មសិទ្ធិម៉ាក (Assignment) សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ………………………………. ៦០ ០០០រៀល<br>- ការកត់ត្រា ការប្តូរឈ្មោះ ឬការរួមបញ្ចូលគ្នា នៃម្ចាស់ម៉ាក (Name Change and Merger) សម្រាប់មួយម៉ាក និងមួយជំពូក មាន តម្លៃ……………………………………. ៦០ ០០០រៀល<br>- ការកែតម្រូវនានា (ជាកំហុសរបស់អ្នកដាក់ពាក្យ) សម្រាប់មួយម៉ាក និងជំពូកមានតម្លៃ…………………………………. ៦០ ០០០រៀល<br>- ការកត់ត្រា ការប្តូរឈ្មោះអាសយដ្ឋាន (Address Change) (ក្នុងករណីប្តូរតែអាសយដ្ឋានមួយប៉ុណ្ណោះ) សម្រាប់មួយម៉ាក និងមួយជំពូក មានតម្លៃ………………………….… ៦០ ០០០រៀល<br>**IV-ការលុបម៉ាក**<br>ការលុបម៉ាកចេញពីបញ្ជី (បង់ដោយអ្នកស្នើលុប) មួយវិញ្ញាបនប័ត្រ មានតម្លៃ…………………………………………… ៣០០ ០០០រៀល<br>**V-ការចុះបញ្ជីម៉ាកសារជាថ្មី**<br>ការដាក់ពាក្យ និងការចុះបញ្ជីម៉ាកសារជាថ្មី មួយវិញ្ញាបនប័ត្រ មានតម្លៃ………………………………………………… ៣០០ ០០០រៀល<br>**VI-ការបោះពុម្ពផ្សេងទៀត (ប្រសិនបើមាន)**<br>- ទំហំតូចជាង១/៣នៃក្រដាសA4មួយឯកត្តាមានតម្លៃ...៦០ ០០០រៀល<br>- ទំហំ១/៣ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ……១២០ ០០០ រៀល<br>- ទំហំ១/២ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ……១៨០ ០០០ រៀល<br>- ទំហំ៣/៤ នៃក្រដាស A4 មួយឯកត្តា មានតម្លៃ…..៣០០ ០០០ រៀល<br>- ទំហំក្រដាស A4 មួយឯកត្តា មានតម្លៃ…………...៦០០ ០០០ រៀល |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | តម្រូវការឯកសារសម្រាប់ចុះបញ្ជីម៉ាក មានដូចខាងក្រោម<br>- ពាក្យស្នើសុំតាមគំរូលេខ០០១<br>- គំរូម៉ាកបោះពុម្ពឡើងវិញចំនួន ១៥<br>- លិខិតប្រគល់សិទ្ធិតាមគំរូលេខ០០២ (ប្រសិនចាត់តាំងភ្នាក់ងារតំណាង) |

| | |
|---|---|
| **យោបល់** | ដើម្បីជៀសវាងការលួចបន្លំ ឬជម្លោះលើការប្រើប្រាស់ម៉ាកដូច ឬស្រដៀង នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនដល់រូបវន្តបុគ្គល នីតិបុគ្គល អាជីវករ សហគ្រិនទាំងអស់គួរតែយកម៉ាករបស់ខ្លួនមកចុះបញ្ជី ដើម្បីទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ ម៉ាក ដូចខាងក្រោម៖<br>- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះ ដោយជនណាមួយក្រៅពីម្ចាស់ដើមត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកដើមជាមុនសិន<br>- ម្ចាស់ដើមនៃម៉ាក មានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ៗក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវ សញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះ ហើយដែលអាចបណ្តាលឲ្យមានការភ័ន្តច្រឡំជាសាធារណៈ។ ការខកខានមិនបានចុះបញ្ជីការពារម៉ាកអាចនាំដល់ផលវិបាកនានាដូចជា មិនអាចទប់ស្កាត់ ឬប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចប្រឆាំងនឹងអ្នកប្រើប្រាស់ម៉ាកដែលដូច ឬស្រដៀងនឹងម៉ាករបស់ខ្លួនដោយគ្មានការអនុញ្ញាត ឬលំបាកក្នុងការផ្ទេរសិទ្ធិប្រើប្រាស់ម៉ាករបស់ខ្លួនទៅអ្នកដទៃជាដើម។ |

## សេវាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងលើការរៀបចំ និងដាក់តាំងពិព័រណ៍ ពាណិជ្ជកម្ម ការផ្តល់លិខិតអនុញ្ញាតរៀបចំពិព័រណ៍ពាណិជ្ជកម្ម

| | |
|---|---|
| ឈ្មោះសេវា | ការផ្តល់លិខិតអនុញ្ញាតរៀបចំពិព័រណ៍ពាណិជ្ជកម្ម |
| ក្រសួង/ស្ថាប័នផ្តល់សេវា | ក្រសួងពាណិជ្ជកម្ម<br>• នាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម<br>- អាសយដ្ឋាន: ជាន់ទីពីរ នៃអាគារទីស្តីការក្រសួងពាណិជ្ជកម្ម ឡូតិ៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (ផ្លូវលេខ ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- ទូរស័ព្ទលេខ : ០១២ ៨៤២ ១១៩/ ០៩៥ ៥៥៣ ៣៥៥<br>- អ៊ីម៉ែល : sokdarith72@gmail.com / rithyco@yahoo.com |
| គោលបំណងនៃការផ្តល់សេវា | • គ្រប់គ្រងរាល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មទាំងអស់ក្នុងប្រទេសកម្ពុជា<br>• កត់ត្រានូវចំនួនពិព័រណ៍ដែលបានរៀបចំក្នុងប្រទេស ដើម្បីដាក់បញ្ចូលក្នុងប្រតិទិនពិព័រណ៍ប្រចាំឆ្នាំ<br>• ដើម្បីរក្សាភាពប្រកួតប្រជែងដោយសមធម៌ ក្នុងក្របខ័ណ្ឌទីផ្សារសេរី<br>• ការពារមិនឲ្យផ្សព្វផ្សាយ ឬឃោសនាពន្លើសការពិត<br>• ដើម្បីជំរុញ និងគាំទ្រដល់សកម្មភាពពាណិជ្ជកម្ម ក្នុងការជួយអភិវឌ្ឍវិស័យសេដ្ឋកិច្ច |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពី ការប្រកាសឱ្យប្រើនូវច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម<br>• ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើនូវច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម<br>• ព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពី ការប្រកាសឱ្យប្រើនូវច្បាប់ស្តីពី វិសោធនកម្មលើច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្ម<br>• អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ ១៩៨ ពណប្រក.បល ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពី ការប្រព្រឹត្តទៅរបស់នាយកដ្ឋានកិច្ចការពិព័រណ៍<br>• ប្រកាសរួម ១៦៤៣ សហវប្រក. ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការកែប្រែកម្រងសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម |
| អតិថិជនដែលមានសិទ្ធទទួលសេវា | ក្រុមហ៊ុនក្នុងស្រុក ឬបរទេស បណ្តាអង្គការ សមាគម ឬស្ថាប័នផ្សេងៗ ដែលរៀបចំពិព័រណ៍ពាណិជ្ជកម្ម ។ ការរៀបចំពិព័រណ៍ពាណិជ្ជកម្ម ឬពិព័រណ៍មានលក្ខណៈពាណិជ្ជកម្ម បើទុកណាប្រធានបទជាប្រភេទវិជ្ជាជីវៈក៏ដោយ គឺការរៀបចំពិព័រណ៍ទាំងនោះ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម ដូច្នេះមុននឹងរៀបចំពិព័រណ៍ត្រូវសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្មជាមុនសិន |
| ស្តង់ដាសេវា | • សេវារហ័សមិនអូសបន្លាយពេលវេលា ផ្តល់សេវាតាមលក្ខខណ្ឌ កំណត់រយៈពេល០៧ ថ្ងៃ នៃថ្ងៃការងារ (ក្នុង០១លើក)<br>• តម្លៃនៃការផ្តល់សេវាៈ<br>១.ការចេញលិខិតអនុញ្ញាតរៀបចំពិព័រណ៍............................1,400,000៛ |

| | |
|---|---|
| | ២.កម្រៃនៃការគ្រប់គ្រង និងចាត់ចែងពិព័រណ៍(គិតក្នុង០១ស្តង់)<br>- វិស័យទូទៅ(ប្រធានបទពាក់ព័ន្ធនឹងវិជ្ជាជីវៈ)..............100,000៛<br>- ពិព័រណ៍ដែលមានប្រធានបទបម្រើវិស័យកសិកម្មជាលក្ខណៈអន្តរជាតិ...................................................................20,000៛<br>៣.កម្រៃកក្តីលើសេវារៀបចំពិព័រណ៍ 8% នៃចំណូលសរុប(ក្នុង០១លើក)<br>រយៈពេលនៃការផ្តល់សេវា០១ថ្ងៃ នៃថ្ងៃធ្វើការ។ |
| **តម្រូវការឯកសារ ដើម្បីទទួលបានសេវា** | ដើម្បីសុំលិខិតអនុញ្ញាត បណ្តាក្រុមហ៊ុន អង្គការ សមាគម និងស្ថាប័នធ្វើអាជីវកម្ម សេវាកម្មពិព័រណ៍ពាណិជ្ជកម្មត្រូវតែមានក្រុមហ៊ុនពិតប្រាកដដែលបានចុះបញ្ជីក្រុមហ៊ុននៅក្នុងក្រសួងពាណិជ្ជកម្ម ដោយកំណត់កម្មវត្ថុអាជីវកម្មរបស់ខ្លួននៅក្នុងលក្ខន្តិកៈនៃក្រុមហ៊ុន។ រាល់ការរៀបចំតាំងពិព័រណ៍ពាណិជ្ជកម្មត្រូវកំណត់ឲ្យបានច្បាស់លាស់នូវប្រធានបទពិព័រណ៍ ពេលវេលា ទីតាំងរៀបចំព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកដែលត្រូវរៀបចំពិព័រណ៍។ ឯកសារបន្ថែមផ្សេងៗទៀត អ្នករៀបចំតាំងពិព័រណ៍ទាំងអស់ត្រូវមាន៖<br>- ពាក្យស្នើសុំរៀបចំពិព័រណ៍ (ឯកសារដើម)របស់អ្នករៀបចំពិព័រណ៍ ចំនួន.....................................................................០១ ច្បាប់<br>- លិខិតចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម (ថតចម្លង) ចំនួន.......................................................................០១ ច្បាប់<br>- ប័ណ្ណប៉ាតង់ ឆ្នាំចុងក្រោយ (ថតចម្លង)ចំនួន......................០១ច្បាប់ |
| **យោបល់** | សូមអញ្ជើញសេវាករប្រភេទនេះទាំងអស់ មកទាក់ទងដល់ទីកន្លែងផ្តល់សេវាកម្មដោយផ្ទាល់ ដើម្បីទទួលបានសេវាកម្មស្របច្បាប់ |

# សេវាដែលពាក់ព័ន្ធនឹង

## ១. សេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល រួមជាមួយស្ថាប័នគយ និងរដ្ឋាករ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

## ២. វិញ្ញាបនបត្រកម្មចំពោះទំនិញនាំចេញតាមសំណើរបស់អ្នកស្នើសុំដើម្បីបំពេញលក្ខខណ្ឌតម្រូវតាមប្រទេសនាំចូល

## ៣. ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និងការបង្ក្រាបការក្លែងបន្លំ

| | |
|---|---|
| ឈ្មោះសេវា | - សេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ<br>- វិញ្ញាបនបត្រកម្មចំពោះទំនិញនាំចេញតាមសំណើរបស់អ្នកស្នើសុំដើម្បីបំពេញលក្ខខណ្ឌតម្រូវតាមប្រទេសនាំចូល<br>- ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និង ការបង្ក្រាបការក្លែងបន្លំ |
| ក្រសួង/ស្ថាប័ន ផ្តល់សេវា | **ក្រសួងពាណិជ្ជកម្ម**<br>• អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ<br>- អាសយដ្ឋាន: លេខ៥០Eo ផ្លូវ១៤៤ សង្កាត់ផ្សារកណ្ដាល១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ/ទូរសារ៖ (៨៥៥)២៣ ៤២៦ ១៦៦<br>- អ៊ីម៉ែល ៖ cpd@camnet.com |
| គោលបំណង នៃការផ្តល់សេវា | • ធានាគុណភាព សុវត្ថិភាពផលិតផល (ម្ហូបអាហារ និងមិនមែនម្ហូបអាហារ) និងសេវា និងការពារអ្នកប្រើប្រាស់<br>• ធានាកិច្ចការពារពាណិជ្ជកម្មប្រកបដោយសមធម៌<br>• ធានាអនុលោមភាពនៃបណ្តាលក្ខខណ្ឌតម្រូវផ្នែកច្បាប់ពាក់ព័ន្ធនឹងពាណិជ្ជកម្ម<br>• ទទួលផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មជាលក្ខណៈភាគីទី៣<br>• ជំរុញឲផលិតផលម្ហូបអាហារ ផលិតផលមិនមែនម្ហូបអាហារលក់លើទីផ្សារមានគុណភាព សុវត្ថិភាព ការពារផលប្រយោជន៍អ្នកប្រើប្រាស់<br>• ផ្តល់សេវាការពារដល់អ្នកប្រើប្រាស់តាមការឃ្លាំពិនិត្យទីផ្សារ និងការបង្រាបការក្លែងបន្លំ |
| មូលដ្ឋានគតិយុត្ត | • ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ស្តីពី ការដាក់ឲប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា<br>• អនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពី ការតម្លើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឲទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)<br>• សារាចរណែនាំអន្តរក្រសួងលេខ២៥៦ ពណផកសរណន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៤ ស្តីពី សោហ៊ុយត្រួតពិនិត្យទំនិញនាំចេញ-នាំចូលរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>• ប្រកាសអន្តរក្រសួងលេខ០១ ប្រក.កយ ២០០៤ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពី ការដាក់ឲប្រើប្រាស់គំរូសំណុំលិខិតដោះស្រាយបទល្មើសស្តីពី |

| | |
|---|---|
| | គុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវាដលើមន្ត្រីនគរបាលយុត្តិធម៌របស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ០០៧ MoC/M ២០០៤ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៤ ស្តីពី វិធានការហាមឃាត់ការនាំចូលជាបណ្តោះអាសន្ននូវបក្សី ស៊ុតបក្សី សាច់បក្សីស្រស់ និងក្លាស្សេ និងផលិតផលមានដើមកំណើតពីបក្សី<br>• ប្រកាសអន្តរក្រសួងលេខ៩៩៤សហវ.ប្រកចុះថ្ងៃទី០៦ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពី ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ<br>• ប្រកាសរួមលេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម |
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | គ្រប់ការីសេដ្ឋកិច្ចពាក់ព័ន្ធការធ្វើពាណិជ្ជកម្មជាអាទិ៍ការនាំចេញ-នាំចូលការផលិតកែច្នៃ ការស្តុកទុក និងការលក់ចែកចាយទំនិញ និងអ្នកប្រើប្រាស់ទូទៅ |
| **ស្តង់ដាសេវា** | កម្រៃសេវាត្រួតពិនិត្យត្រូវបានកំណត់តាមប្រភេទត្រួតពិនិត្យ និងផលិតផល ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក |
| **តម្រូវការឯកសារដើម្បីទទួលបានសេវា** | សំណើពិនិត្យលក្ខណៈសម្បត្តិសម្រាប់នាំចេញ-នាំចូលតាមការផ្តល់ដំណឹង នៃការ នាំចេញ-នាំចូលជាក់ស្តែង (ពាក្យស្នើសុំ) ក្នុងក្របខណ្ឌនៃការអនុវត្តវិធីសាស្ត្រគ្រប់គ្រងហានិភ័យដោយមានឯកសារគាំទ្រ៖<br>- អញ្ញត្តិប័ត្រ (B/L)<br>- វិក្កយបត្រ និង បញ្ជីវេចខ្ចប់ (Invoice and Packing List)<br>- ឯកសារពាក់ព័ន្ធ និង កិច្ចធានាគុណភាព សុវត្ថិភាព ទិសដៅប្រើប្រាស់ (ជាក់ស្តែងតាមប្រភេទទំនិញ) តាមការចាំបាច់ |
| **យោបល់** | • ការផ្តល់សេវានេះ ជាបទដ្ឋានគតិយុត្តសំខាន់បំផុតសម្រាប់ឈានទៅការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាក្នុងទិសដៅធានាឲ្យបាននូវផលប្រយោជន៍របស់អតិថិជន ក្នុងការធ្វើពាណិជ្ជកម្មដោយស្មោះត្រង់ និងយុត្តិធម៌ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មដោយស្មោះត្រង់ និងយុត្តិធម៌ ផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ<br>• សេវានេះ(លើកលែងតែការត្រួតពិនិត្យពាណិជ្ជកម្មជាលក្ខណៈភាគីទី៣) មានលក្ខណៈជាច្បាប់<br>• ចំពោះការត្រួតពិនិត្យពាណិជ្ជកម្មលក្ខណៈជាភាគីទី៣ អង្គភាពត្រួតពិនិត្យពាណិជ្ជកម្ម នៃអគ្គនាយកដ្ឋានមានទំនុកចិត្តពីអតិថិជនបរទេសជាច្រើន។ ការប្រើប្រាស់សេវានេះនឹងមានលក្ខណៈពិតប្រាកដក្នុងកិច្ចធានាការបំពេញបំណងរបស់អតិថិជន |

## **វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ** ( Certificate of Origin "C/O" )

| | |
|---|---|
| ឈ្មោះសេវា | វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ( Certificate of Origin "C/O" ) |
| ក្រសួង/ស្ថាប័នផ្តល់សេវា | **ក្រសួងពាណិជ្ជកម្ម**<br>• នាយកដ្ឋាននាំចេញ-នាំចូល<br>- អាសយដ្ឋាន: ឡូត៍លេខ១៩-៦១វិថីក្រសួងពាណិជ្ជកម្ម (ផ្លូវលេខ ១១៣បេ) សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>- ទូរស័ព្ទ: ០២៣ ៨៦៦ ៤៦៩<br>- អ៊ីម៉ែល: hosivyong@yahoo.com |
| គោលបំណងនៃការផ្តល់សេវា | • គ្រប់គ្រងទំនិញនាំចេញនាំចូលតាមច្បាប់ និងបទប្បញ្ញត្តិដែលកំណត់ដោយរាជរដ្ឋាភិបាល<br>• ផ្តល់ជូនអ្នកនាំចេញនូវវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ( Certificate of Origin "C/O" ) ពីប្រទេសកម្ពុជានាំចេញទៅក្រៅប្រទេស |
| មូលដ្ឋានគតិយុត្ត | • អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ ១៧៨ ព.ណនច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ របស់ក្រសួង ពាណិជ្ជកម្ម ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននាំចេញ នាំចូល<br>• ប្រកាសលេខ ១៤៣៧ ពណប.អព 99 ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការចេញវិញ្ញាបនបត្រប្រភពដើមទំនិញ វិក្កយបត្រពាណិជ្ជកម្ម និងអាជ្ញាប័ណ្ណនាំចេញ ចំពោះទំនិញសម្លៀកបំពាក់សម្រាប់នាំចេញ<br>• ប្រកាសលេខ 265MOC/M2002 ចុះថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញជូនអង្គការក្រៅរដ្ឋាភិបាល ( NGOs )<br>• ប្រកាសលេខ ១៩៣MOC/SM2006 ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៦ របស់ក្រសួង ពាណិជ្ជកម្ម ស្តីពីការបង់កម្រៃគ្រប់គ្រងការនាំចេញ សម្រាប់សម្លៀកបំពាក់អនាម័យដែលប្រើតែមួយលើក រួចបោះចោល<br>• ប្រកាសលេខ ១១២MOC/SM2013 ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការកែសម្រួលនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ<br>• ប្រកាសអន្តរក្រសួងលេខ ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ រវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស<br>• ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាង ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពី ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម<br>• ប្រកាសលេខ ១៦១ព.ណ.ពពក.ប្រក ចុះថ្ងៃទី៣០ខែឧសភាឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យអនុវត្តសាកល្បងនូវការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមប្រព័ន្ធអេឡិចត្រូនិច |

| | |
|---|---|
| **អតិថិជនដែលមានសិទ្ធទទួលសេវា** | នីតិបុគ្គល |
| **ស្តង់ដាសេវា** | ដោយអនុវត្តតាមខ្លឹមសារប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ចាប់ពីពេលដាក់ពាក្យ ស្នើសុំរហូត ដល់ពេលទទួលយកវិញ្ញាបនបត្រប្រភពដើមទំនិញ (C/O) គឺមានរយៈពេល ១១ម៉៥៥នាទី នៃម៉ោងធ្វើការ សុពលភាព ៦-១២ខែ។<br>**តម្លៃនៃការផ្តល់សេវា៖**<br>១.សម្លៀកបំពាក់<br>• <u>C/O ទម្រង់ A :</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........58$+EMF<br>• តិចជាង2,000PCS..........23$+EMF<br>• <u>C/O ទម្រង់ N :</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........38$+EMF<br>• តិចជាង2,000PCS..........18$+EMF<br>• <u>C/O ទម្រង់ផ្សេងទៀត</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........58$+EMF<br>• តិចជាង2,000PCS..........23$+EMF<br>២.ក្រណាត់<br>• C/O ទម្រង់ A..........58$+EMF<br>• C/O ទម្រង់ N..........38$+EMF<br>• C/O ទម្រង់ផ្សេងទៀត..........58$+EMF<br>៣.ស្បែកជើង<br>• <u>C/O ទម្រង់ A :</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........58$+EMF<br>• តិចជាង2,000PCS..........23$+EMF<br>• <u>C/O ទម្រង់ N :</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........38$+EMF<br>• តិចជាង2,000PCS..........18$+EMF<br>• <u>C/O ទម្រង់ផ្សេងទៀត</u><br>• ច្រើនជាង ឬស្មើ 2,000PCS..........58$+EMF<br>• តិចជាង2,000PCS..........23$+EMF<br>៤.អង្ករ<br>• C/O ទម្រង់ A..........200,000៛+EMF<br>• C/O ទម្រង់ N..........120,000៛+EMF<br>• C/O ទម្រង់ផ្សេវទៀត..........200,000៛+EMF<br>៥.ទំនិញសិប្បកម្មតូច<br>• C/O គ្រប់ទម្រង់..........មិនគិតថ្លៃ<br>៦.ទំនិញទូទៅ<br>• C/O ទម្រង់ A..........58$+EMF<br>• C/O ទម្រង់ N..........38$+EMF |

| | |
|---|---|
| | • C/O ទម្រង់ផ្សេងទៀត..........................................................58$+EMF<br>៧.ការកែតម្រូវ ឬចេញច្បាប់ទុតិយតានៃវិញ្ញាបនបត្រប្រភពដើមទំនិញ<br>• C/O ទម្រង់ A :<br>• ច្រើនជាង ឬស្មើ 2,000PCS/PRS................................................58$<br>• តិចជាង2,000PCS/PRS............................................................23$<br>• C/O ទម្រង់ N :<br>• ច្រើនជាង ឬស្មើ 2,000PCS/PRS................................................38$<br>• តិចជាង2,000PCS/PRS............................................................18$<br>• C/O ទម្រង់ផ្សេងទៀត<br>• ច្រើនជាង ឬស្មើ 2,000PCS/PRS................................................58$<br>• តិចជាង2,000PCSPRS.............................................................23$ |
| តម្រូវការឯកសារ ដើម្បីទទួលបានសេវា | ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖<br><br>១. ការនាំចេញតាមជើងនាវា (By Sea)<br>**ក- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសម្ភារៈប្រើប្រាស់ផ្សេងទៀត ដូចជា កាបូប មួក ជាដើម**<br>• ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន<br>• លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ<br>• បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ<br>• វិក័យប័ត្រ (Invoice)<br>• តារាងវេចខ្ចប់ ( Packing List)<br>• អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)<br>• កំណត់ហេតុរួមស្តីពី ការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល<br>• ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>• លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនឲ្យតំណាងរបស់ខ្លួន<br>**ខ- ផលិតផលផ្សេងទៀត ក្រៅពីសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ និងស្បែកជើង**<br>• ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន<br>• លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ<br>• បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ<br>• វិក័យប័ត្រ (Invoice)<br>• តារាងវេចខ្ចប់ ( Packing List)<br>• អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)<br>• ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)<br>• វិញ្ញាបនបត្របញ្ជាក់បរិមាណទំនិញនាំចេញរបស់អគ្គនាយកដ្ឋានកាំកុងត្រូល (CQ)<br>• ប្រតិវេទន៍គយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD) |

- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុនដែលអាចបញ្ជាក់ពីប្រភពដើម ទំនិញ
- អាជ្ញាប័ណ្ណនាំចេញ (ចំពោះទំនិញដែលច្បាប់តម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចេញ)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនឲ្យតំណាងរបស់ខ្លួន

**គ- ទំនិញជាផលិតផលសិប្បកម្មតូច និងកសិកម្ម**

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការកំណត់ដោយបញ្ញត្តិ
- វិក័យប័ត្រ (Invoice)
- តារាងវេចខ្ចប់ ( Packing List)
- អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)
- វិញ្ញាបនបត្របញ្ជាក់បរិមាណទំនិញនាំចេញរបស់អគ្គនាយកដ្ឋានកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (CD)
- ឯកសារពាក់ព័ន្ធរបស់ក្រុមហ៊ុន ដែលអាចបញ្ជាក់ពីប្រភពដើមទំនិញ (ករណីអង្ករ និងផលិតផលកសិកម្មដែលមានលក្ខណៈរសើបមួយចំនួន)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនឲ្យតំណាងរបស់ខ្លួន

**ឃ- ទំនិញសម្លៀកបំពាក់ពណ៌ប៉ារ៉ា ពណ៌បៃតង (ត្រេអ៊ី និងកាគី)**

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន
- ពាក្យស្នើសុំចុះត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្ម សមត្ថភាពផលិតកម្ម និង ផ្ទៀងផ្ទាត់ជាមួយសន្និធិនាំចេញ-នាំចូលនៃវត្ថុធាតុដើម
- របាយការណ៍របស់មន្ត្រីត្រួតពិនិត្យសង្វាក់ផលិតកម្ម និងផលិតផលនាំចេញ
- លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- វិក័យប័ត្រ (Invoice)
- តារាងវេចខ្ចប់ ( Packing List)
- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឲ្យតំណាងរបស់ខ្លួន ក្រោយពេលចេញទំនិញរួច ត្រូវប្រគល់ជូនបន្ថែមនូវឯកសារ ដូចខាងក្រោម ៖
- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមនាវា ឬតាមជើងយន្តហោះ (Bill of Lading/Airway Bill)
- កំណត់ហេតុរួមស្តីពី ការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល
- ប្រតិវេទន៍ចេញពីកម្ពុជា (Cambodia Outward Declaration)

២. <u>ការនាំចេញតាមជើងយន្តហោះ</u> ( By Air)

**ក- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសម្ភារៈ**

| | |
|---|---|
| | **ប្រើប្រាស់ផ្សេងទៀត ដូចជា កាបូប ម្ជុក ជាដើម**<br>• ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន<br>• លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ<br>• បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ<br>• វិក័យប័ត្រ (Invoice)<br>• តារាងវេចខ្ចប់ ( Packing List)<br>• លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនឲ្យតំណាងរបស់ខ្លួន ក្រោយពេលចេញទំនិញរួច ត្រូវប្រគល់ជូនបន្ថែមនូវឯកសារ ដូចខាងក្រោម:<br>- អញ្ញត្តិប័ណ្ណដឹកជញ្ជូន ( Airway Bill )<br>- កំណត់ហេតុរួមស្តីពី ការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល<br>- ប្រតិវេទន៍ចេញពីកម្ពុជា ( Cambodia Outward Declaration )<br>**ខ- ទំនិញជាផលិតផលសិប្បកម្មតូច និងកសិកម្ម**<br>• ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន<br>• លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការកំណត់ដោយប្បញ្ញត្តិ<br>• វិក័យប័ត្រ (Invoice)<br>• តារាងវេចខ្ចប់ ( Packing List)<br>• លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឲ្យតំណាងរបស់ខ្លួន ក្រោយពេលចេញទំនិញរួច ត្រូវប្រគល់ជូនបន្ថែមនូវឯកសារ ដូចខាងក្រោម ៖<br>- អញ្ញត្តិប័ណ្ណដឹកជញ្ជូន ( Airway Bill )<br>- កំណត់ហេតុរួមស្តីពី ការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល<br>- ប្រតិវេទន៍ចេញពីកម្ពុជា ( Cambodia Outward Declaration )<br>៣ . <u>**ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ផលិតផលធ្វើពីស្បែក និងផលិតផលដទៃទៀត ដែលដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនកម្ពុជាទៅឡើងយន្តហោះនៅប្រទេសជិតខាង**</u> ( Land-Air )<br>• ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ក្រុមហ៊ុន<br>• លិខិតបញ្ជាក់ពីការបង់សោហ៊ុយរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ<br>• បង្កាន់ដៃបង់ប្រាក់កម្រៃសេវាសាធារណៈ<br>• វិក័យប័ត្រ (Invoice)<br>• តារាងវេចខ្ចប់ ( Packing List)<br>• របាយការណ៍របស់មន្ត្រីត្រួតពិនិត្យសង្វាក់ផលិតកម្ម និង |

ផលិតផលនាំចេញ

- លិខិតឧទ្ទេសនាម និងផ្ទេរសិទ្ធិរបស់ក្រុមហ៊ុនឲ្យតំណាងរបស់ខ្លួន ក្រោយពេលចេញទំនិញរយៈពេល៣០ថ្ងៃ ត្រូវប្រគល់ជូនបន្ថែមនូវឯកសារ ដូចខាងក្រោម ៖
  - អញ្ញត្តិប័ណ្ណដឹកជញ្ជូន ( Airway Bill )
  - កំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានកាំកុងត្រូល
  - ប្រតិវេទន៍ចេញពីកម្ពុជា ( Cambodia Outward Declaration )

4. <u>ការនាំចេញតាមរថយន្ត</u> ( By Truck)

**ក- ទំនិញសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងសម្ភារៈប្រើប្រាស់ផ្សេងទៀត ដូចជា កាបូប មួក ជាដើម**

